ស.អ.ក
សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

# របាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា ប្រចាំខែមេសា ២០២០ និងបួនខែ ដើមឆ្នាំ២០២០

# Cambodian Rice Export Summary Report
## April 2020 and 4 months of 2020

#2C, Street 120, Sangkat Phsar Tmey II, Khan Daun Penh, Phnom Penh, Cambodia

www.crf.org.kh info@crf.org.kh (855) 23 559 8999

## ការនាំចេញអង្កររបស់កម្ពុជា ៤ខែ ដើមឆ្នាំ២០២០ កើនដល់កម្រិត ខ្ពស់ជាងគេ ក្នុងរយៈពេល ១០ឆ្នាំ




កម្ពុជាសំរេចការនាំចេញអង្កររបស់ខ្លួនក្នុងរយៈពេល៤ខែដំបូងនៃឆ្នាំ ២០២០ បានជាង៣០ម៉ឺនតោន ដែលបរិមាណនេះស្មើនឹងជាង៤៨% នៃការនាំចេញសរុប របស់ឆ្នាំ២០១៩។ ការនាំចេញ៤ខែដំបូង មាន ចំនួន ៣០០,២៥២ តោន គឺមាន កំណើនចំនួន ៤១% បើប្រៀប ជាមួយ៤ខែ ដើមឆ្នាំ ២០១៩ ដែលនាំចេញបានប្រមាណចំនួនត្រឹមតែ ២១៣,៧៦៣ តោន តែប៉ុណ្ណោះ។ នេះជាកំនើនមួយ ដែលគួរឲ្យកត់ សំគាល់បំផុតរបស់កម្ពុជា ដែលបានសំរេចការនាំចេញ មានតួលេខខ្ពស់បំផុត ក្នុងរយៈពេល៤ខែដើមឆ្នាំ នៃការនាំចេញរបស់កម្ពុជា ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយ។ ដោយឡែកសំរាប់ខែមេសា ឆ្នាំ២០២០ នេះ ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានខិតខំយកចិត្តទុកដាក់ គិតគូរយ៉ាងហ្មត់ចត់ ចំពោះសន្តិសុខ ស្បៀងសំរាប់ប្រជាពលរដ្ឋកម្ពុជា ដោយផ្អាកការនាំចេញ "អង្ករស" មួយរយៈពេលខ្លីក៏ដោយ ក៏ការនាំចេញ អង្ករក្រអូប របស់កម្ពុជា បានសម្រេចជាង ៦៩ពាន់តោន ដែលផ្តល់នូវតំលៃមួយយ៉ាងខ្ពស់សំរាប់អាជីវករ និងអ្នករកស៊ីនៅក្នុងវិស័យស្រូវអង្ករ។







## Cambodian rice export peak in 10 years for the 4 months of 2020

Cambodia exported rice in the total amount of more than 300,000 tonnes for the 4 months of 2020, generating as 48% of the total export amount in 2019. For this first 4 months of 2020, Cambodia exported rice in the amount of 300,252 tonnes, increased by 41% comparing to the same period in 2019, which exported only 213,763 tonnes. This is considered as the most significant growth of Cambodia, which achieved the highest amount for the first four months in the last 10 years history. Despite the government consideration in food security for Cambodian people by banning the "White Rice" export at the temporary period from the early April 2020, the fragrant rice is still exported in the total amount of more than 69,000 tonnes; providing the high price for rice merchants and businesses in rice sector.

ប្រភពទិន្នន័យ៖ ច្រកចេញចូលតែមួយ អគ្គនាយកដ្ឋានកសិកម្ម និង ទិន្នន័យផ្សព្វផ្សាយលើទំព័រ facebook ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

Source: One Window Service of General Directorate of Agriculture of MAFF and Facebook Page of H.E Veng Sakhon, Minister of the Ministry of Agriculture, Forestry, and Fisheries




ការនាំចេញអង្ករកម្ពុជា ក្នុងខែមេសាឆ្នាំ២០២០ គឺយើងសង្កេតឃើញថា ជាង ៣៩% គឺបាន នាំទៅប្រទេសនៅទ្វីបអ៊ឺរ៉ុប ជាង៣០%ទៅប្រទេសចិន ជាង១៣%ទៅបណ្តាប្រទេសនៅក្នុង រដ្ឋសមាជិកអាស៊ាន ជាពិសេសប្រទេសម៉ាឡេស៊ី និង ព្រុយណេ ហើយ ១៨% ទៅកាន់តំបន់ ផ្សេងៗដែលក្នុងនោះប្រទេសអូស្ត្រាលី ញូហ្សេឡែន មានការកើនឡើងគួរអោយកត់សំគាល់។ ការនាំចេញនេះ គឺ មានកំនើនជាង ៦១%ប្រៀបធៀបទៅខែមេសា ឆ្នាំ ២០១៩ដូចគ្នា។

ម្យ៉ាងទៀតក្នុង រយៈពេល៤ខែដើមឆ្នាំ ២០២០ នេះគឺប្រទេសកម្ពុជាបាននាំចេញទៅកាន់ ប្រទេសចិន ចំនួន ៤១%  ស្មើនឹង ១២២០៩៤ តោន ទៅកាន់សហគមន៍អ៊ឺរ៉ុប និងប្រទេស អង់គ្លេស មានចំនួន ៣២% ស្មើ ៩៧៣៣៧ តោន ប្រទេសនៅក្នុងសហគមន៍អាស៊ាន មាន ចំនួន១៣% ចំនួន ៣៧៤២៨តោន និងបណ្តាប្រទេសផ្សេងៗ មានចំនួន១៤% ឬ ៤៣៣៩៣តោន។

បើយើងពិនិត្យមើលកំណើន តាមគោលដៅនីមួយយើងឃើញថា បណ្តាប្រទេសគោលដៅ ផ្សេងៗដែលក្នុងនោះមានប្រទេសអូស្តាលី ញូហ្សេឡែន កាប៉ុង មានកំនើនខ្ពស់ជាង៧៩% សហគមន៍អ៊ឺរ៉ុបមានកំនើន ៤៩% ប្រទេសក្នុងតំបន់អាស៊ាន ២៩% និង ប្រទេសចិនមានចំនួន ២៨% ដែលកំនើនជារួមគឺ ៤០% ប្រៀបទៅឆ្នាំ២០១៩។

In April 2020, Cambodia exported rice to the market destinations such as 39% to European Union ( EU ), 30% to China, more than 13% to ASEAN countries, especially Malaysia and Brunei, and 18% to other destinations such as Australia and New Zealand that are noticeably increasews.  The Overall export of April 2020 is increased by 61% comparing to April 2019.

Moreover, in the first 4 months of 2020, Cambodia exported rice to China in the amount of 122,094 tonnes ( 41% ), to EU and British 97,337 tonnes ( 32% ), to ASEAN countries 37,428 tonnes ( 13% ), and other destinations 43,393 tonnes ( 14% ).

In term of percentage increasing of each market destinations, Australia, New Zealand, and Gabon have highly increased up to 79%, EU up to 49%, ASEAN countries up to 29%, China up to 28%, and for the overall is 40% increase comparing to 2019.




**សហព័ន្ធស្រូវអង្ករកម្ពុជា** ( Cambodia Rice Federation )

ប្រធានក្រុមប្រឹក្សាភិបាល ( Chairman )
លោកឧកញ៉ា ហ៊ុន ឡាក់ ( Oknha Hun Lak )
ប្រធានសហព័ន្ធ  ( President )
លោកឧកញ៉ា សុង សារ៉ន ( Okhna Song Saran )
អគ្គលេខាធិការ ( Secretary General )
លោក លន់ យ៉េង ( Mr. Lun Yeng )

ដកស្រង់ និងវិភាគដោយ ( Cited and Analysed by )
លោក លន់ យ៉េង- អគ្គលេខាធិការ
( Mr. Lun Yeng  - Secretary General )

រចនាដោយ ( Designed by )
កញ្ញា សន ឆវីវតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង
( Ms. Sorn Chhorvyvatey - Communication Coordinator )

**ប្រភពទិន្នន័យ៖** ច្រកចេញចូលតែមួយ អគ្គនាយកដ្ឋានកសិកម្ម និង ទិន្នន័យផ្សព្វផ្សាយលើទំព័រ facebook ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

Source: One Window Service of General Directorate of Agriculture of MAFF and Facebook Page of H.E Veng Sakhon,  Minister of the Ministry of Agriculture, Forestry, and  Fisheries